Khmer | ភាសាខ្មែរ

BreastScreen Victoria

# សិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក

## ឯកសារនេះរៀបរាប់ជាលម្អិតអំពីសិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក នៅពេលអ្នកប្រើសេវាកម្ម BreastScreen Victoria។

| | អ្នកមានសិទ្ធិ៖ | អ្នកទទួលខុសត្រូវចំពោះ៖ |
|---|---|---|
| **ការចូលប្រើប្រាស់** | • ទៅគ្លីនិក BreastScreen Victoria ណាមួយក៏បាន<br>• ទទួលបានការថតពិនិត្យ និងការវាយតម្លៃដោះដោយឥតគិតថ្លៃ | • ការជូនដំណឹងមកយើង ប្រសិនបើអ្នកមានតម្រូវការពិសេសណាមួយ |
| **សុវត្ថិភាព** | • ទទួលបានការថែទាំប្រកបដោយសុវត្ថិភាព និងមានគុណភាពខ្ពស់<br>• ទទួលព័ត៌មាន ដើម្បីឱ្យអ្នកអាចធ្វើការជ្រើសរើសបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ | • ការប្រកាន់អាកប្បកិរិយាដែលនឹងមិនបង្កផលអវិជ្ជមានដល់សុវត្ថិភាព សុខុមាលភាព ឬសិទ្ធិនានារបស់បុគ្គលិក និងភ្ញៀវដទៃទៀតដែលប្រើប្រាស់សេវាកម្ម<br>• ការយល់ដឹងថាអ្នកអាចត្រូវបានស្នើសុំឱ្យចាកចេញ ឬត្រូវបានដកចេញពីការថែទាំ ប្រសិនបើអ្នកមិនគោរពបុគ្គលិក ឬភ្ញៀវដទៃទៀតដែលប្រើប្រាស់សេវាកម្ម ឬបង្ហាញឫកពាគំរាមកំហែង ឬបង្កគ្រោះថ្នាក់ |
| **គោរព** | • បទពិសោធន៍ប្រកបដោយការគោរព និងសមគួរតាម វប្បធម៌<br>• ទទួលគ្លីនិកដែលស្អាត មានផាសុកភាព និងឯកជន | • ការគោរពចំពោះបុគ្គលិកដែលថែទាំអ្នក និងភ្ញៀវដទៃទៀតដែល ប្រើប្រាស់សេវាកម្មរបស់យើង<br>• ការជូនដំណឹងមកយើង អំពីតម្រូវការនានារបស់អ្នកក្នុងលក្ខណៈគួរសម |
| **ការប្រាស្រ័យទាក់ទង** | • ទទួលការប្រាស្រ័យទាក់ទងច្បាស់លាស់ និងបើកចំហជាមួយបុគ្គលិករបស់យើង<br>• សួរសំណួរនានា<br>• ទទួលព័ត៌មានដ៏មានប្រយោជន៍ដែលអ្នកអាចយល់បាន<br>• ប្រើអ្នកបកប្រែផ្ទាល់មាត់ | • ការផ្តល់ព័ត៌មានត្រឹមត្រូវមកយើង ដើម្បីឱ្យយើងអាចជួយអ្នកបាន<br>• ការជូនដំណឹងមកយើង ប្រសិនបើអ្នកមានសំណួរ ឬកង្វល់ណាមួយអំពីការថែទាំរបស់អ្នក |
| **ការចូលរួម** | • សុំឱ្យយើងផ្អាកនៅពេលណាក៏បាន<br>• ដកការយល់ព្រមរបស់អ្នកនៅពេលណាក៏បាន<br>• នាំសមាជិកគ្រួសារ ឬអ្នកគាំទ្រមកជាមួយអ្នក | • ការផ្តល់ព័ត៌មានណាមួយមកយើងដែលយើងត្រូវការដើម្បីការថែទាំអ្នក |
| **ឯកជនភាព** | • រំពឹងថាពួកយើងនឹងរក្សាភាពឯកជនរបស់អ្នក<br>• ដាក់ពាក្យដើម្បីចូលមើលឬសុំព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក<br><br>ស្នើសុំបុគ្គលិករបស់យើងនូវច្បាប់ចម្លងនៃគោលការណ៍ឯកជនភាពរបស់យើង ឬចូលមើលគេហទំព័រ breastscreen.org.au | • ការជូនដំណឹងមកយើង ប្រសិនបើព័ត៌មានសុខភាពណាមួយរបស់អ្នកមិនត្រឹមត្រូវ ឬមិនពេញលេញ |
| **មតិយោបល់** | • រំពឹងថាយើងនឹងឆ្លើយតបចំពោះកង្វល់ណាមួយដែលអ្នកមាន<br><br>ទាក់ទងទៅស្នងការគ្រប់គ្រងបណ្តឹងតវ៉ាផ្នែកសុខភាព ប្រសិនបើបញ្ហានៅតែមិនអាចដោះស្រាយបានទេនោះ។ | • ការបញ្ចេញមតិយោបល់ ឬលើកឡើងពីកង្វល់ណាមួយអំពីការថែទាំអ្នក<br><br>ដាក់ស្នើមតិកែលម្អនៅ breastscreen.org.au ឬទូរសព្ទទៅលេខ 13 20 50។ |



សូមមើលម្ខាងទៀត →

## កម្មវិធីរបស់យើងគឺមានការគោរព និងស្វាគមន៍

យើងប្តេជ្ញាធានាថាកម្មវិធីរបស់យើងមានលក្ខណៈរួមបញ្ចូល ដោយផ្តល់លទ្ធភាពដល់ពលរដ្ឋវិចថូរៀគ្រប់រូបដែលមានសិទ្ធិប្រើប្រាស់សេវានេះ។ យើងរៀបចំកម្មវិធីសហគមន៍នានាដើម្បីដោះស្រាយឧបសគ្គដែលរារាំងការថតពិនិត្យដោះ និងដើម្បីបង្កើនការចូលរួមនៅក្នុងកម្មវិធីរបស់យើង។

សម្រាប់ព័ត៌មានបន្ថែមអំពីជំនួយដល់សហគមន៍ មានជូន
នៅ BreastScreen Victoria សូមចូលទៅកាន់គេហទំព័រ
www.breastscreen.org.au/community-support/

## ព័ត៌មានបន្ថែម

សូមសួរបុគ្គលិករបស់យើង ប្រសិនបើអ្នកមានសំណួរ ឬកង្វល់ណាមួយ។ សិទ្ធិ និងទំនួលខុសត្រូវរបស់យើងគឺផ្អែកលើធម្មនុញ្ញអូស្ត្រាលីអំពីសិទ្ធិថែទាំសុខភាព (Australian Charter of HealthCare Rights) នៅរដ្ឋវិចថូរៀ។

## កក់ទុកការណាត់នៅតាមគេហទំព័រ **breastscreen.org.au** ឬទូរសព្ទទៅលេខ **13 20 50**

**TTY 13 36 77** ប្រសិនបើអ្នកមានការពិបាកស្តាប់ ឬបញ្ហានៃការនិយាយ

សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីកែប្តូរព័ត៌មានលម្អិតរបស់អ្នក សូមចូលទៅកាន់គេហទំព័រ **breastscreen.org.au** ឬទូរសព្ទទៅលេខ **13 20 50**

សម្រាប់ជំនួយអ្នកបកប្រែផ្ទាល់មាត់ សូមទូរសព្ទទៅលេខ **13 14 50**

ព័ត៌មានដែលមានការបកប្រែ៖
**breastscreen.org.au/translations**

BreastScreen Victoria សូមទទួលស្គាល់នូវជំនួយពីរដ្ឋាភិបាលរដ្ឋវិចថូរៀ។



© 2023 BreastScreen Victoria។ រក្សាសិទ្ធិគ្រប់យ៉ាង

**ខែកក្កដា ឆ្នាំ 2023** FSR&R/0723